# កម្មវិធីឡជីវឧស្ម័នថ្នាក់ជាតិ

NBP

## ការគ្រប់គ្រង និងប្រើប្រាស់ជីកាកសំណល់ឡជីវឧស្ម័ន



កសិករមានឡជីវឧស្ម័នមួយ ប្រៀបដូចជាមានកន្លែងផលិតជីមួយនៅតាមផ្ទះ

រៀបចំដោយ: កម្មវិធីឡជីវឧស្ម័នថ្នាក់ជាតិ

បោះពុម្ពលើកទី ១ ខែ កក្កដា ២០១១

# ១. អ្វីទៅជាកាកសំណល់ឡជីវឧស្ម័ន?





**គឺជា**ល្បាយលាមកសត្វដែលហូរចេញពីឡជីវឧស្ម័នបន្ទាប់ពីបានឆ្លងកាត់ដំណើរការបំបែកធាតុ ក្នុងលក្ខខ័ណគ្មានខ្យល់អុកស៊ីសែន។

**លក្ខណៈពិសេស៖** គ្មានក្លិនស្អុយ  គ្មានគ្រាប់ស្មៅ និងបរាសិត  មានសារធាតុចិញ្ចឹមច្រើនប្រភេទ និងស្ថិតក្នុងទំរង់ដែលរុក្ខជាតិងាយស្រូបយក។

# ២. អាងស្តុកកាកសំណល់ឡារ







## សារៈប្រយោជន៍របស់អាងស្តុកកាកសំណល់ឡារ

- ងាយស្រួលនៅពេលចង់ប្រើកាកសំណល់ឡារជាជីទឹក
- ងាយស្រួលដួសសំរាប់លាយជាមួយសារធាតុសរីរាង្គក្នុងរណ្តៅជី
- បរិវេណផ្ទះមានអនាម័យស្អាត

*អាងស្តុកកាកសំណល់ឡារ គួរតែស្របតាមបណ្តោយឡ និងមានទំហំមធ្យម ១ ម$^{៣}$*